# ការគ្រប់គ្រងការបំពេញការងាររបស់អង្គការ

ដោយ ឡេងឆាយ

## 1. ការគ្រប់គ្រងការបំពេញការងារ: ជាវិធីមួយបែបប្រព័ន្ធ

តើកត្តាអ្វីដែលនាំទៅរកលទ្ធផលការងារអង្គការខ្ពស់? ចំលើយដែលគេនឹកឃើញភ្លាមៗនោះអាចជា: បុគ្គលិកដែលមានសមត្ថភាព និងមានការប្តេជ្ញាខ្ពស់។ ប៉ុន្តែមានបញ្ហាអ្វីប្រសិនបើបុគ្គលិកមានសមត្ថភាពនិងការប្តេជ្ញាខ្ពស់ តែលទ្ធផលកាងារអង្គការនៅតែមានកំរិតទាប?

ដើម្បីទទួលបានលទ្ធផលការងារអង្គការខ្ពស់ អ្នកត្រូវមានការគិតអោយបានពេញលេញដោយពិចារណាលើកត្តាផ្សេងៗដែលមានឥទ្ធិពល។ គំរូសាមញ្ញមួយបាននិយាយថា: មានកត្តាសំខាន់ៗបីត្រូវពិចារណាដើម្បីទទួលបានលទ្ធផលអង្គការខ្ពស់: បុគ្គលិក ដំណើរការ និងគោលដៅ។ ជារឿយៗ ការមិនបានសំរេចលទ្ធផលមិនបណ្តាលមកពីបុគ្គលិកឡើយ តែវាបណ្តាលមកពីប្រព័ន្ធ នីតិវិធី និងរបៀបធ្វើការងារដែលមានលក្ខណ:ស្មុគស្មាញនិងមិនមានប្រសិទ្ធផល ឬបណ្តាលមកពីគោលដៅ និងលទ្ធផលរំពឹងទុក ដែលមានលក្ខណ:លោភលន់ពេក។ ប្រការនេះ ការកែកសំរួលប្រព័ន្ធការងារ ឬបញ្ចុះការរំពឹងទុក នឹងនាំអោយយើងសំរេចលទ្ធផលការងារ។

- សមត្ថភាព
- ការប្តេជ្ញាចិត្ត
- ចំនួនបុគ្គលិក




- គោលដៅ/គោលបំណង
- លទ្ធផលរំពឹងទុក

នីតិវិធីធ្វើការងារ ប្រព័ន្ធ វិធីសាស្ត្រ/របៀបធ្វើការងារ

This learning article shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.

## 2. កត្តាចំរុះដែលមានឥទ្ធិពលលើលទ្ធផលការងារៈ មានប្លង់ពីរ

### កត្តាដែលមានឥទ្ធិពលដល់លទ្ធផលការងាររអង្គការ

| លំដាប់ការងារ | គោលដៅ GOALS | ការរៀបចំDESIGN | ការគ្រប់គ្រង MANAGEMENT |
|---|---|---|---|
| លំដាប់ អង្គការ | គោលដៅអង្គការ<br>ទិសដៅនិងយុទ្ធសាស្ត្រអង្គការ | ការរៀបចំអង្គការ<br>ការរៀបចំមុខងារ ប្រព័ន្ធនានា និងរចនាសម្ព័ន្ធក្នុងអង្គការ | ការគ្រប់គ្រងអង្គការ<br>បង្កើតគោលដៅអង្គការ គ្រប់គ្រងមុខងារនានា បែងចែកធនធាន |
| លំដាប់ ដំណើរការ | គោលដៅដំណើរការ<br>គោលដៅនៃដំណើរការសំខាន់ៗ ដែលទាក់ទងនឹងតំរូវការរបស់អង្គការ | ការរៀបចំដំណើរការ<br>ប្រសិទ្ធភាព និងប្រសិទ្ធផលនៃដំណើរដែល បានរៀបចំដើម្បីសំរេចគោលដៅរបស់វា | ការគ្រប់គ្រងដំណើរការ<br>គ្រប់គ្រងដំណើរការ បែងចែកធនធានសំរាប់ដំណើរការ |
| លំដាប់មុខការងារម្នាក់ៗ/ អ្នកអនុវត្តការងារ | គោលដៅការងារ/អ្នកអនុវត្ត<br>លទ្ធផលនិងស្តង់ដានៃមុខតំណែងមួយ ដែលរំពឹងអោយមាន | ការរៀបចំការងារម្នាក់ៗ<br>រៀបចំការងារអោយត្រឹមត្រូវ សមស្របតាមបរិយាកាស និងលក្ខខណ្ឌនានា | ការគ្រប់គ្រងការងារបុគ្គលិក<br>ការយល់ដឹងរបស់បុគ្គលិកលើកាងារ ។ ចំណេះដឹងនិងជំនាញដែលបុគ្គលិកត្រូវការ ដើម្បីសំរេចគោលដៅការងារ |

បញ្ជាក់: សូមបកស្រាយតារាងពីឆ្វេងទៅស្តាំ ជាជាងពីក្រោមទៅលើ។

This learning article shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.